**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៥៤/១៥ ក.អ.ជ.ប្រក

ថ្ងៃ ចន្ទ ៥ កើត ខែទុតិយាសាឍ ឆ្នាំ មមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា គ.ស. ២០១៥

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពអង្គភាពគ្រប់គ្រងគម្រោងកែលម្អផ្លូវជនបទជំហានទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងហិរញ្ញប្បទានពីមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចកូរ៉េ (EDCF)

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងកំណត់ហេតុកិច្ចប្រជុំចរចាឥណទានរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី
- យោងប្រកាសលេខ ១៥៩/១៤ ក.អ.ជ.ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា គ.ស. ២០១៤ ស្តីពីការបង្កើត និងតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ សម្រាប់បំពេញការងារនៅក្នុងអង្គភាពគ្រប់គ្រងគម្រោងកែលម្អផ្លូវជនបទជំហានទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងហិរញ្ញប្បទានពីមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចកូរ៉េ (EDCF)
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ១.-** សម្រួលភារកិច្ចលោក **មេង សៅតាក់គុណា** ពីមន្ត្រីផ្នែកវិភាគសេដ្ឋកិច្ចគម្រោង ។



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

**ប្រការ ២.-** តែងតាំងលោកបណ្ឌិត **ថុល ឌីណា** ជាមន្ត្រីផ្នែកវិភាគសេដ្ឋកិច្ចគម្រោង ។

**ប្រការ ៣.-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>កន្លែងទទួល</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ ១*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*

ជា សុផារ៉ា